ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៩ខែដើមឆ្នាំ២០១៤ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

ក្នុងរយៈពេល៩ខែ ឆ្នាំ២០១៤នេះ ស្ថានភាពការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៤ បានកត់សម្គាល់ឃើញថា បរិមាណទឹកភ្លៀងបានធ្លាក់ជាមធ្យមគ្រប់តំបន់ទូទាំងប្រទេស។ មកទល់ពេលនេះ ល្បឿនការងារដាំដុះដំណាំស្រូវសម្រេចបាន១០០,៣៨ភាគរយ នៃផែនការនិងមានសភាពយឺតជាងឆ្នាំមុន(៤,០៧ភាគរយ) បើប្រៀបធៀបរយៈពេលដូចគ្នា ហើយខេត្តចំនួន១២ត្រូវបានបញ្ចប់ និងអនុវត្តលើសផែនការ (លើកលែងតែខេត្តរតនគីរីសម្រេចបាន២៥.៩២៥ហិកតា ស្មើនឹង៩៧,៨៣ភាគរយ នៃផែនការ២៦.៥០០ហិកតា)។ ជាមួយនេះ ប្រជាកសិករកំពុងបន្តការងារបង្កបង្កើនផលដំណាំរដូវវស្សាយ៉ាងសកម្ម ជាពិសេសខិតខំជំរុញការថែទាំសន្ទូងនិងធ្វើកសិកម្មសម្រុះ។ រីឯការខូចខាតដំណាំ ស្រូវដោយគ្រោះធម្មជាតិមកទល់ពេលនេះ អាចវាយតម្លៃជារួមប្រមាណ១.៥៩ភាគរយ នៃផ្ទៃដីអនុវត្តបាន។ ក្រសួងក៏បានណែនាំដល់អង្គភាពជំនាញក្រោមឱវាទនិងមន្ទីរកសិកម្មរាជធានី ខេត្ត បន្តវាយតម្លៃផលប៉ះពាល់ ក៏ដូចជាការខូចខាតលើផលដំណាំ ជាពិសេសជួយអន្តរាគមន៍ស្តារឡើងវិញលើការប៉ះពាល់ខូចខាតដោយគ្រោះទឹកជំនន់ និងគ្រោះរាំងទឹក។ រីឯលទ្ធផលនិងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗទៀតដែលសម្រេចបានក្នុងរយៈពេល៩ខែដើមឆ្នាំ២០១៤នេះ ដូចខាងក្រោម៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

#### ១.១ ដំណាំស្រូវរដូវវស្សាឆ្នាំ២០១៤

-ផ្ទៃដីភ្ជួររាស់សរុបចំនួន២.៨៤០.៨៤៧ហិកតា (ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីចំនួន៦៦០.៣២៤ហិកតា ស្មើនឹង២៣,២៤% និងគ្រឿងយន្តចំនួន២.១៨០.៥២៣ហិកតា ស្មើនឹង៧៦,៧៦%) តិចជាងឆ្នាំមុនចំនួន៣៣៥.៦៤៣ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំចំនួន២១២.៤៤៦ហិកតា

-ផ្ទៃដីសាបសរុបចំនួន១១២.៩៨៩ហិកតា តិចជាងឆ្នាំមុនចំនួន៤៥.៦៧៧ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំចំនួន៧២.០៤២ហិកតា

-ផ្ទៃដីសន្ទូងនិងពង្រោះសរុបចំនួន២.៤២០.៤៤៩ហិកតា ស្មើនឹង១០០,៣៨ភាគរយនៃផែនការ២.៤១១.២០៧ហិកតា តិចជាងឆ្នាំមុនចំនួន៨៦.០២០ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំចំនួន៣២.០២៤ហិកតា រួមមាន៖

- ស្រូវស្រាលចំនួន៦០៨.៧៣៧ហិកតា (ក្នុងនោះស្រូវបង្កើនរដូវចំនួន១៧៦.៨៨៣ហិកតា) តិចជាងឆ្នាំមុនចំនួន៣៤.៩០៥ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំចំនួន៥.៤០៥ហិកតា
- ស្រូវកណ្តាលចំនួន១.១៨៦.៦៥៨ហិកតា តិចជាងឆ្នាំមុនចំនួន១៦.៦១៥ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំចំនួន៥០.៨៩២ហិកតា



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
No. 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129 Fax : (855) 23 217 320

- ស្រូវធ្ងន់ចំនួន៥២៨.៤៩៦ហិកតា តិចជាងឆ្នាំមុនចំនួន១៧.៦៣៣ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំចំនួន១២.៨៥៨ហិកតា
- ស្រូវចម្ការចំនួន៤៤.០៧៧ហិកតា តិចជាងឆ្នាំមុនចំនួន៣.៣៩១ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំចំនួន៥.៤៩២ហិកតា
- ស្រូវឡើងទឹកចំនួន៥២.៤៨១ហិកតា តិចជាងឆ្នាំមុនចំនួន១៣.៤៧៦ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំចំនួន៣១.៦៣៩ហិកតា។

**១.២ ដំណាំរួមផ្សំ**

ផ្ទៃដីសម្រេចបានចំនួន៦៦១.១០៨ហិកតា ស្មើនឹង១២៥,២១% នៃផែនការចំនួន៥២៨.០១៨ហិកតា លើសឆ្នាំមុនចំនួន៤៤.១៣៥ហិកតា។

**១.៣ ដំណាំឧស្សាហកម្ម**

ផ្ទៃដីសម្រេចបាន១២១.៧០៥ហិកតា ស្មើនឹង៧៧,៥២% នៃផែនការ១៥៧.០០៧ហិកតា តិចជាងឆ្នាំមុនចំនួន១៦.៨៣១ហិកតា។

**១.៤ ការងារប្រមូលផលស្រូវស្រាលដើមរដូវវស្សាឆ្នាំ២០១៤**

ការងារប្រមូលផលស្រូវស្រាលដើមរដូវសម្រេចបានលើផ្ទៃដីសរុបចំនួន១៨៤.៨៥៩ហិកតា តិចជាងឆ្នាំមុន២៦.៥០៣ហិកតា ដោយទទួលបានបរិមាណផលសរុបចំនួន៦៧៤.៧៤១តោន តិចជាងឆ្នាំមុន១០៦.៦១១តោន និងទិន្នផលជាមធ្យមចំនួន៣,៦៥០តោនក្នុងមួយហិកតា លើសឆ្នាំមុន៤៧គីឡូក្រាមក្នុងមួយហិកតា។

**១.៥ ស្ថានភាពប៉ះពាល់និងខូចខាតដោយគ្រោះធម្មជាតិ**

-គ្រោះរាំងស្ងួត៖ ប៉ះពាល់លើផ្ទៃដីសរុបចំនួន៩៦.៩៥៣ហិកតា ក្នុងនោះសំណាបសរុបចំនួន៧.៦៤៦ហិកតា និងសន្ទូង-ពង្រោះសរុបចំនួន៨៩.៣០៧ហិកតា។ សំណាបខូចខាតអស់ចំនួន១.៩១២ហិកតា សន្ទូង-ពង្រោះខូចខាតចំនួន១៧.៥៣៧ហិកតា និងស្តារសំណាបបានចំនួន២១៧ហិកតា និងសន្ទូង-ពង្រោះចំនួន៧.២៧១ហិកតា(តារាងជូនភ្ជាប់)

-គ្រោះទឹកជំនន់៖ ប៉ះពាល់លើផ្ទៃដីសរុបចំនួន៧៨.២៣៦ហិកតា ក្នុងនោះសំណាបសរុបចំនួន២៣៤ហិកតា និងសន្ទូង-ពង្រោះសរុបចំនួន៧៨.០០២ហិកតា។ សំណាបខូចខាតអស់ចំនួន៧០ហិកតា និងសន្ទូង-ពង្រោះខូចខាតចំនួន២០.៨៧៣ហិកតា និងស្តារបានសន្ទូង-ពង្រោះចំនួន៤.២៨៨ហិកតា(តារាងជូនភ្ជាប់)។

សូមជម្រាបជូនថា ដំណាំរួមផ្សំដែលទទួលរងនូវផលប៉ះពាល់រហូតមកដល់ពេលនេះមិនមានទិន្នន័យប្រែប្រួលឡើយ។ ដំណាំពោតប៉ះពាល់ចំនួន៣.៤៣២ហិកតា ក្នុងនោះខូចខាតចំនួន១.៦៨០ហិកតា ដំណាំដំឡូងមីប៉ះពាល់ចំនួន៣៣២ហិកតា ក្នុងនោះខូចខាតចំនួន៩៩ហិកតា និងបន្លែប៉ះពាល់ចំនួន៧៣៩ហិកតា ក្នុងនោះខូចខាតចំនួន១៩៩ហិកតា។

**១.៦ ការងារអន្តរាគមន៍**

ឆ្លើយតបទៅនឹងបញ្ហាគ្រោះធម្មជាតិ (ទឹកជំនន់រាំងស្ងួត) អគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផលិតពូជដំណាំដើម្បីត្រៀមអន្តរាគមន៍ដូចខាងក្រោម៖

–ពូជស្រូវ

- ស្បៀងបម្រុងពូជស្រូវសុទ្ធល្អ (IR66 និងផលសារ) បានចំនួន២២០តោន
- គម្រោង EFAT ពូជស្រូវបានចំនួន៤៣៤តោន
- គម្រោង **សម្តេច ហ៊ុន សែន** ពូជស្រូវបានចំនួន៣១៥,៨៤០ តោន

–ពូជដំណាំរួមផ្សំ

ពូជបន្លែគ្រប់មុខ (ផ្ទីស ត្រសក់ ត្រប់វែង ល្ពៅ ប៉េងប៉ោះ សណ្តែកគួរ ពោតដំណើប និងពោតផ្អែម) សរុបបានចំនួន១១.៨៣០គីឡូក្រាម សម្រាប់ចែកជូនប្រជាកសិករដែលរងគ្រោះដោយទឹកជំនន់សម្រាប់យកទៅដាំដុះស្តារឡើងវិញលើការខូចខាត។

### ១.៧ ការងារជំរុញ និងការងារនាំចេញផលិតផលកសិកម្ម

រយៈពេល៩ខែដើមឆ្នាំ២០១៤នេះ (គិតត្រឹមថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៤) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (អគ្គនាយកដ្ឋានកសិកម្ម) បានធ្វើការត្រួតពិនិត្យភូតគាមអនាម័យកសិផលកម្ពុជានាំចេញកសិផលសរុប ២.០២០.៧៨២តោន ក្នុងនោះផលិតផលសំខាន់ៗចំនួន១.៤៧៨.៦០៣តោន រួមមាន៖ អង្ករ២៤៩.៤៦០តោន ចំណិតដំឡូងមីក្រៀម៩៦១.២៧៥តោន ដំឡូងមីស្រស់៣១៧.៦១៣តោន ម្សៅដំឡូងមី៧.០៣៥តោន សណ្តែកសៀង ១៥.៣៣៣តោន ដូងប្រេង២.៧៣៨តោន ពោត៩០.៦៨១តោន គ្រាប់ស្វាយចន្ទី៥១.២១៦តោន និងជ័រកៅស៊ូ ៨៣.២៥២តោន ក្នុងនោះ៖

- ការនាំចេញទៅកាន់ទីផ្សារប្រទេសចិនសម្រេចបាន១១.៧៩៥តោន
- ការនាំចេញដំឡូងមីក្រៀមពីកម្ពុជាទៅប្រទេសចិន អង្គភាពជំនាញបានត្រួតពិនិត្យ វាយតម្លៃនិងចុះបញ្ជីឈ្មោះក្រុមហ៊ុនចំនួន៤៧ក្រុមហ៊ុន ដែលមានលក្ខណៈសម្បត្តិនាំចេញដំឡូងមីក្រៀមកម្ពុជាទៅកាន់ប្រទេសចិនសម្រេចបាន ចំនួន៣៤៤.៨០៧តោន។

## ២ ផ្នែកកៅស៊ូ

### ២.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីដាំដុះនិងថែទាំ ២០០៣-២០១៣(ហ.ត) | ផលិតផលអនុវត្តបាន ដល់ខែនេះ (តោន) | បញ្ចូញលក់ ដល់ខែនេះ(តោន) |
|---|---|---|---|---|---|
| I-ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៤០៦,៦០ | ៣៩៥,៧១ | ៤១៨,៣៤ | ៣៥០,០០ |
| សរុប I | | ៤០៦,៦០ | ៣៩៥,៧១ | ៤១៨,៣៤ | ៣៥០,០០ |
| II-ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុន សុកគ្គីនីកា អ៊ិនវេសមេន គ្រុប | ១០.៧១៩,០០ | ៥.៣២៧,០៥ | ១០.៩៤៩,៣៤ | ៦.០៤៤,៩២ |
| ២ | ក្រុមហ៊ុន ស៊ីហ្វារ៉ាប់ប៊ើលីមីធីត (រតនគីរី) | ៧៨,៥៣ | ១.៦២៥,៩០ | ៤៨២,៥៩ | - |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ១.២៤១,៨០ | ៨៨៥,០១ | ៦៨០,១៣ | ៦០៦,០០ |
| ៤ | ក្រុមហ៊ុន ចម្ការកៅស៊ូបឹងកេត | ២.៥៧១,៥២ | ៣.០៥៨,២៧ | ៣.២៥៦,៧៦ | ២.៦៩៦,៦០ |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣.២៦៨,៧៤ | ៥.៣៤៦,៦៩ | ២.៥៧៧,១៧ | ១.៨០៣,៣៦ |
| ៦ | ក្រុមហ៊ុន ស៊ីហ្វរីសសស់ (ស្នួល) | ១.៦២៣,២០ | ២.៧៦៣,០១ | ១.៣៩៣,២៩ | ១.១៦៦,៨០ |
| ៧ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ពាមជាំង) | ២.០២៩,៧០ | ១.២៣៧,៥៩ | ១.១១២,៥០ | ៨៣៨,២០ |
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ២.០៣៨,០០ | ៣.៤៦៩,៧៩ | ១.០១៤,០៧ | ៧២១,៨០ |
| ៩ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (រមាសហែក) | - | ៨៧៥,៦៦ | - | - |
| ១០ | ក្រុមហ៊ុនក្រែក (ខេមបូឌា) ខូអិលធីឌី | ៣.៣៩៣,៥៥ | ២.០៧៧,៩២ | ៣.២៨២,៤៤ | ២.៧១៣,៤០ |
| សរុប II | | ២៦.៩៦៤,០៤ | ២៦.៦៦៦,៨៩ | ២៤.៧៤៨,២៩ | ១៦.៥៩១,០៨ |
| III-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | | ១៣៥.៤៤៦,០០ | | |
| ១២ | ក្រុមហ៊ុន ចម្ការកៅស៊ូគ្រួសារ | ៦១.២៧១,០០ | ៦៦.១៣៦,០០ | ៣៥.៧១៩,០០ | ៣១.៧៥០,០០ |
| សរុប III | | ៦១.២៧១,០០ | ២០១.៥៨២,០០ | ៣៥.៧១៩,០០ | ៣១.៧៥០,០០ |
| សរុប I+II+III | | ៨៨.៦៤១,៦៤ | ២២៨.៦៤៤,៦០ | ៦០.៨៨៥,៦៣ | ៤៨.៦៩១,០៨ |

**២.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

-បើកវគ្គបណ្ដុះបណ្ដាលដាំដុះនិងថែទាំកៅស៊ូ វគ្គគ្រប់គ្រងច្បារពូជនិងថ្នាលកូន វគ្គប្រមូលទឹកជ័រ វគ្គគ្រប់គ្រងសមាសភាពចង្រៃនិងជំងឺ និងវគ្គកែច្នៃកៅស៊ូសន្លឹកនិងចំណាត់ថ្នាក់ដល់កសិករ

-បញ្ជូនមន្ត្រីជំនាញនិងថ្នាក់ដឹកនាំចំនួន៦រូប ទៅចូលរួមក្នុងកិច្ចប្រជុំនិងសិក្ខាសាលានៅប្រទេសម៉ាឡេស៊ី មីយ៉ាន់ម៉ា និងឥណ្ឌា

-ផ្ដល់មែកពូជចំនួន១៥គ្លូន ស្មើ១.២៧៥ម៉ែត្រ និងដាំពិសោធន៍ក្លូនបានចំនួន៨ពូជ ស្មើ៤.៣១៦ក្លូន លើផ្ទៃដី ៧,៧៧ហិកតា នៅក្រុមហ៊ុនចម្ការកៅស៊ូទ្រីភាពទន្លេម្រេច ស្រុករវៀង ខេត្តព្រះវិហារ

-ចុះយកសំណាកស្លឹកកៅស៊ូដើម្បីវិភាគ DNA បានចំនួន៣.៣៦៨សំណាកក្នុងច្បារពូជ១០៧ នៅខេត្តកំពង់ចាម ត្បូងឃ្មុំ ក្រចេះ ស្ទឹងត្រែង និងខេត្តរតនគិរី

-ចូលរួមធ្វើតេស្តអន្តរមន្ទីរពិសោធន៍ជាមួយ IRA (Information Rubber Association) ចំនួន២លើក និងធ្វើតេស្តប្រៀបធៀបមន្ទីរពិសោធន៍ក្នុងស្រុកបានចំនួន៣លើក

-ដឹកនាំនិស្សិតសរសេរសារណាបទថ្នាក់បរិញ្ញាបត្របានចំនួន១៣នាក់ មកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម សាកលវិទ្យាល័យស្វាយរៀង សាលាជាតិកសិកម្មកំពង់ចាម វិទ្យាស្ថានបច្ចេកទេសកម្ពុជា និងនិស្សិតមកពីប្រទេសបារាំង។

## ៣ ផ្នែកផលិតកម្មនិងបសុព្យាបាល

**៣.១ ការងារស្ថានីយពិសោធន៍ពូជជ្រូក-គោ**

-ជ្រូកសរុបចំនួន២៧៨ក្បាល ក្នុងនោះជ្រូកបាចំនួន១៣ក្បាល ជ្រូកមេចំនួន១០១ក្បាល និងកូនជ្រូកចំនួន១៦៤ក្បាល

-គោសរុបចំនួន១៨៩ក្បាល ក្នុងនោះគោបាចំនួន៤ក្បាល គោមេប្រាម៉ាន់កាត់ចំនួន៦២ក្បាល គោជំទង់ចំនួន៤៩ក្បាល គោបៅដោះចំនួន៣៦ក្បាល និងគោក់ផែងសែនចំនួន៣៨ក្បាល។

**៣.២ ផលប៉ះពាល់លើសត្វដោយទឹកជំនន់**

រហូតមកដល់ពេលនេះសរុបសត្វរងផលប៉ះពាល់រួមមាន៖ គោ-ក្របីចំនួន១៤២.៩០៨ក្បាល ជ្រូកចំនួន៦.៩៦០ក្បាល និងបក្សីចំនួន៧៣.៩៤២ក្បាល។ ក្នុងចំណោមសត្វដែលរងផលប៉ះពាល់ទាំងប៉ុន្មានខាងលើមាន គោ-ក្របីឈឺចំនួន៥១១ក្បាល និងជ្រូកឈឺចំនួន៩១៧ក្បាល។

**៣.៣ ការចាក់ថ្នាំបង្ការជំងឺឆ្លងសត្វ**

-ចាក់ថ្នាំការពារជំងឺឆ្លងលើគោ-ក្របី-ពពែ ជំងឺសារទឹកចំនួន១.០៣៧.៨៥៨ក្បាល ជំងឺអុតក្ដាមចំនួន២៩.១៥៣ក្បាល និងជំងឺបូសខ្យល់ចំនួន៤.៤៨៤ក្បាល

-ចាក់ថ្នាំការពារជំងឺឆ្លងលើសត្វជ្រូក ជំងឺសារទឹកចំនួន៧៣.៨៥៣ក្បាល ជំងឺប៉េស្តចំនួន១១១.២១៤ក្បាល ជំងឺសាល់ម៉ូណេឡូសចំនួន៧៥.៩៤៥ក្បាល ជំងឺអុតក្ដាមចំនួន៥.៧១២ក្បាល ជំងឺអូហ្យេស្គីចំនួន១០.៤៩៩ក្បាល ជំងឺរាគកូនជ្រូកចំនួន១៨.៩៤៩ក្បាល ជំងឺក្រញ៉ូលចំនួន១៥០ក្បាល ជំងឺជាតិដែកចំនួន១២.៦៥៣ក្បាល និងជំងឺផ្លូវដង្ហើមចំនួន១.៧៨៩ក្បាល

-ចាក់ថ្នាំការពារជំងឺឆ្លងលើបក្សី ជំងឺអុតចំនួន១៤៧.៧៣៩ក្បាល ជំងឺញ៉ូវកាសចំនួន៣២៨.៣៨៥ក្បាល ជំងឺអាសន្នរោគចំនួន៣៧១.០១២ក្បាល ជំងឺហ្គុមបូរ៉ូចំនួន៣.៤៣២ក្បាល និងជំងឺប៉េស្តទាចំនួន១១៤.១៣៦ក្បាល។

**៣.៤ ការងារបសុព្យាបាល**

-ចុះអង្កេតស្រាវជ្រាវកន្លែងផ្ទុះជំងឺអុតក្ដាម ជំងឺសារទឹក ជំងឺបូសខ្យល់ និងជំងឺប៉េស្តជ្រូក

-រៀបចំធ្វើឲ្យប្រសើរឡើងការងារតាមដានព័ត៌មានសុខភាពសត្វ

-អង្កេតស្រាវជ្រាវ តាមដានឃ្លាំមើល និងយកវត្ថុវិភាគ ស្ដីពីជំងឺផ្ដាសាយបក្សីនិងជំងឺទូទៅនៅរាជធានី ខេត្ត

-បានពិនិត្យវត្ថុវិភាគសរុបចំនួន៥.០៨៨សំណាក និងផ្នែកសរីរោគសាស្ត្រសរុបចំនួន១១៣ក្បាល

-ចុះផ្សព្វផ្សាយអត្ថប្រយោជន៍ឡជីវឧស្ម័ន និងផលិតឡជីវឧស្ម័នសរុបចំនួន១.៣២៦ឡ។

-តាមដាន ឃ្លាំមើលជាប្រចាំនូវជំងឺផ្តាសាយបក្សីប្រភេទH5N1 និងH7N9 នៅលើទីផ្សាររាជធានី ខេត្តទូទាំងប្រទេស និងទទួលទូរស័ព្ទមកពីតាមបណ្តារាជធានី ខេត្ត វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា និងក្រសួងសុខាភិបាល សាកសួរពីរោគសញ្ញា វិធានការការពារ ការធ្វើជីវសុវត្ថិភាព រាយការណ៍ពីបក្សីឈឺ ងាប់ និងករណីមនុស្សឈឺដោយសារជំងឺផ្តាសាយបក្សី

-ធ្វើការឃាត់ចាប់បទល្មើស២៤ករណី ដោយឃាត់ចាប់ក្របីចំនួន១១ក្បាល ជ្រូកចំនួន១៦៧ក្បាល មាន់ចំនួន១១.៧០៣ក្បាល ទាចំនួន៥.០០០ក្បាល ស៊ុតចំនួន១២០.៥០០គ្រាប់ ស្បែកគោ-ក្របីចំនួន១៨.៨៣១គ.ក្រនិងផលិតផលខូចគុណភាពចំនួន៥.៨០៤គ.ក្រ

-ធ្វើការរឹបអូសបានចំនួន២៣លើក និងធ្វើការផាកពិន័យជាទឹកប្រាក់ចំនួន៧៩.៦២០.០០០រៀល

-ចុះធ្វើការបាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងចិញ្ចឹមគោចំនួន២១លើក ក្របីចំនួន១៣លើក ជ្រូកចំនួន២៥៦លើក មាន់ចំនួន៨៨២លើក ទាចំនួន៦៨១លើក កន្លែងពិឃាតមាន់ចំនួន៩០លើក កន្លែងលក់មាន់ចំនួន១៨លើក ទ្រុងចិញ្ចឹមចំនួន១.០០៨លើក បរិវេណភូមិចំនួន៥៨លើក សត្តឃាតដ្ឋានចំនួន៣៥៤លើក ផ្លូវជាតិចំនួន៧លើក និងកន្លែងផ្សេងៗចំនួន៣.៣៨៨លើក

ក្នុងរយៈពេល៩ខែដើមឆ្នាំ២០១៤នេះ មានករណីផ្ទុះជំងឺផ្តាសាយបក្សីប្រភេទ H5N1 ចំនួន៥ករណី គឺនៅក្នុងភូមិស្វាយព្រៃ ឃុំសណ្តែក ស្រុកបាធាយ ខេត្តកំពង់ចាម ភូមិពាមល្វា ឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ភូមិទួលសង្កែ ឃុំកំពង់គុង ស្រុកកោះធំ ខេត្តកណ្តាល ភូមិកណ្តាល ឃុំវត្តអង្គខាងត្បូង ស្រុកបន្ទាយមាស ខេត្តកំពត និងវិទ្យាស្ថានជាតិស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានចាត់ក្រុមអន្តរាគមន៍ចុះប្រតិបត្តិការជាប្រចាំដើម្បីធ្វើការទប់ស្កាត់ចលនាបក្សី និងផលិតផលបក្សីដែលនាំចូលពីប្រទេសជិតខាងដោយខុសច្បាប់ដោយបានអនុវត្តវិធានការបសុពេទ្យជាក់ស្តែង ព្រមទាំងបានណែនាំប្រជាពលរដ្ឋ និងអាជីវករឲ្យយល់ដឹងពីផលវិបាកដែលបណ្តាលមកពីជំងឺផ្តាសាយបក្សី។ ក្រោយសភាពជំងឺផ្តាសាយបក្សីស្ងប់ស្ងាត់ ក្រសួងបានប្រកាសរំសាយតំបន់ជំងឺផ្តាសាយបក្សីចំនួន៤កន្លែង ដូចបានរៀបរាប់ខាងលើ។

## ៤ ផ្នែកព្រៃឈើ

### ៤.១ ការងារព្រៃឈើនិងសហគមន៍ព្រៃឈើ

-ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ(LP) ជូនក្រុមហ៊ុននិងអតិថិជន៖ ឈើហ៊ុបមូលសរុបចំនួន១០៧.០៦៨ម៣ ឈើអារចំនួន៥.១៤៦ម៣ ឈើជ្រុងចំនួន១០.៥៧៦ម៣ កូនឈើចំនួន១.៣២១.៥១៨ដើម និងអុសចម្រុះចំនួន១៦៥.០៩២ស្ទែរ ព្រមទាំងផលិតផលផល អនុផលព្រៃឈើផ្សេងៗទៀត

-គ្រប់គ្រងព្រៃការពារនិងតំបន់អភិរក្សសត្វព្រៃចំនួន១,៦លានហិកតា និងបានបង្កើតព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃសៀមប៉ាង ដែលមានទំហំ៦៦.៩៣២ហិកតា នៅក្នុងខេត្តស្ទឹងត្រែង

-រៀបចំសេចក្តីព្រាងប្រកាសស្តីពីការបង្កើត និងគ្រប់គ្រងតំបន់ព្រៃសហគមន៍ស្ថិតក្នុងខេត្តចំនួន៤ មានសហគមន៍ព្រៃឈើចំនួន១៩កន្លែង គ្របដណ្តប់លើផ្ទៃដីសរុបចំនួន២១.០២៤,០៦ហិកតា

-ចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ចំនួន២០សហគមន៍ ដែលមានផ្ទៃដីព្រៃសរុបចំនួន២៥.៥៤៣ហិកតា ស្ថិតក្នុងខេត្តព្រះវិហារ ខេត្តកំពង់ធំ និងខេត្តកំពង់ស្ពឺ

-សហគមន៍ព្រៃឈើឆ្នើមចំនួន៥ត្រូវបានជ្រើសរើសឲ្យចូលរួមសន្និបាតកសិករ ក្នុងនោះមាន សហគមន៍ព្រៃឈើត្រពាំងក្បាលខ្មោច ខេត្តកំពង់ធំ សហគមន៍ព្រៃឈើព្រៃក្រឡាច ខេត្តបាត់ដំបង សហគមន៍ព្រៃឈើក្រូចឬង ខេត្តកំពង់ស្ពឺ សហគមន៍ព្រៃឈើក្បាលទឹក ខេត្តសៀមរាប និងសហគមន៍ព្រៃឈើក្រាំងធំ ខេត្តពោធិ៍សាត់ ដែលមានអ្នកចូលរួមចំនួន៤៣នាក់ (ស្ត្រីចំនួន៦នាក់)។

### ៤.២ ការងារអភិរក្សធនធានជីវចម្រុះនិងសត្វព្រៃ

-ធ្វើការកត់ត្រាសត្វស្លាបនៅតាមតំបន់អភិរក្សសត្វស្លាបសំខាន់ៗចំនួន២០១ប្រភេទ ប្រមាណ៥៣.៣៤៥ក្បាល (វត្តមានសត្វក្រៀលនៅតំបន់អាងត្រពាំងថ្មមានចំនួនប្រមាណជិត៤០០ក្បាល)

-ដាក់ម៉ាស៊ីនថតស្វ័យប្រវត្តិ៧៦គ្រឿង នៅតំបន់ព្រៃការពារភ្នំក្រវាញភាគកណ្តាលដោយបានកត់ត្រាវត្តមានប្រភេទសត្វដំរី ខ្លារខិន ខ្លាពពក ខ្លាឃ្មុំតូច ឆ្មាព្រៃ ឆ្កែព្រៃ ប្រើស និងកំពឹងដូង ...។ល។ ព្រមទាំងធ្វើជំរឿនទូទាំងប្រទេស បានបង្ហាញវត្តមានសត្វក្រយ៉ងចង្កំ ក ស សរុបប្រមាណ៨០៥ក្បាល ដោយសហការជាមួយអង្គការ WCS និង BIRDLIFE

-ចុះស្រាវជ្រាវនិងអង្កេតសត្វព្រៃក្រុមប្រភេទជិតផុតពូជ និងក្រុមប្រភេទមានដោយកម្រសរុបចំនួន៩លើក នៅតំបន់ព្រៃការពារមណ្ឌលគិរី និងព្រៃការពារព្រះវិហារ ដោយបានកត់ត្រាវត្តមានប្រភេទសត្វជិតផុតពូជរួមមាន រមាំង ដំរី ខ្លាឃ្មុំធំ ក្របីព្រៃ ក្រយ៉ងយក្ស ក្រយ៉ងចង្កំ ក ស និងអង្គត់ខ្មៅ ព្រមទាំងក្រុមប្រភេទមានដោយកម្រ ខ្ទីង ទន្សោង ខ្លារខិន ខ្លាលឿងមាស រញ្ជី ត្មាតផេះ ត្មាតត្នោត ត្មាតភ្លើង ក្រៀល...។ល។

-រៀបចំអាហារដ្ឋានត្មាតចំនួន៣២លើក នៅខេត្តព្រះវិហារ ស្ទឹងត្រែង និងក្រចេះ ដោយរាប់ឃើញសត្វត្មាតសរុបចំនួនជាង២០០ក្បាល

-ការពារសម្បុកសត្វក្រយ៉ងយក្សចំនួន២០ និងសត្វក្រៀលចំនួន១៨ ត្រដក់តូចចំនួន៦៩ វំពេទន្លេចំនួន២២ និងក្រយ៉ងចង្កុះកសចំនួន៤៩ នៅខេត្តព្រះវិហារ ស្ទឹងត្រែង និងក្រចេះ។

### ៤.៣ ការងារអប់រំផ្សព្វផ្សាយនិងបណ្តុះបណ្តាល

-ធ្វើការអប់រំផ្សព្វផ្សាយបានចំនួន១៦៦លើក ស្តីពីរ៉េដបូក ច្បាប់ស្តីពីព្រៃឈើ លើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋាន កម្មវិធីស្រ្ស៊មិត្តសង្គ្រោះសត្វព្រៃ ទប់ស្កាត់ការកាប់រានទីជម្រក និងផ្តល់ចំណេះដឹងអំពីបរិស្ថាននិងការអភិរក្សសត្វស្លាប ដែលមានប្រជាពលរដ្ឋចូលរួមសរុបចំនួន៤.៧២៦នាក់ (ស្ត្រីចំនួន២.១៧៩នាក់)។

### ៤.៤ កសិដ្ឋានចិញ្ចឹម ការបង្កាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

-ក្នុង៩ខែដើមឆ្នាំ២០១៤នេះ ការងារនៅឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹមនិងថែរក្សា៖ សត្វចំណូលថ្មីចំនួន៦៨៧ក្បាល សត្វកើតថ្មីចំនួន៤០ក្បាល សត្វដោះលែងចំនួន៥៨៨ក្បាល សត្វស្លាប់ចំនួន៩២ក្បាល ព្យាបាលសត្វចំនួន២១៣ក្បាល យកសំណាកទៅពិសោធន៍ចំនួន៨៥ក្បាល ធ្វើឲ្យសន្លប់ចំនួន២៥២ក្បាល ទម្លាក់សត្វល្អិតចំនួន២៨៧ក្បាល វះកាត់សាកសពសត្វចំនួន៤៦ក្បាល ដាក់លេខកូដចំនួន៣៨ក្បាល ចាក់វ៉ាក់សាំងចំនួន១.២៤៧ក្បាល សាងសង់របងហ៊ុំព័ទ្ធនិងទ្រុងសត្វថ្មីលើចំនួន៥.២៨៣ម² ជួសជុលទ្រុងសត្វនិងអគារផ្សេងៗចំនួន៥៨ម² ជួសជុលផ្លូវចំនួន១០៤.៤១០ម² សាងសង់សំណង់ផ្សេងៗចំនួន២៨៤ម² ថ្នាលអនាម័យព្រៃចំនួន២១៩.៩២៦ម² ដាំកូនឈើចំនួន៦.២០៦ដើម បណ្តុះថ្នាលម្លូចំនួន៩.៨០១ដើម និងអប់រំផ្សព្វផ្សាយដល់សិស្សានុសិស្សបានចំនួន៦.០២៣នាក់

-ក្រុមហ៊ុនចំនួន០៧ កំពុងចិញ្ចឹមស្វាក្តាមមេ-បាពូជ និងកូនស្វាក្តាមចំនួន៥៦.២១៧ក្បាល និងបាននាំចេញចំនួន៤.៦៩១ក្បាល។

### ៤.៥ គម្រោងអភិរក្សសត្វក្រពើភ្នំកម្ពុជា អភិរក្សធនធានសេនេទិច និងប្រភេទគ្រាប់ពូជ

-បន្តការល្បាតដោយក្រុមល្បាតសហគមន៍ចំនួន២២នាក់ នៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន៤គឺនៅអារ៉ែងឆាយរាប តំបន់ស្លាក្រពើក្នុងឃុំតាតៃលើ ខេត្តកោះកុង និងអូរសោម ខេត្តពោធិ៍សាត់

-តាមដានសត្វក្រពើដែលបានដោះលែង១៥ក្បាល តាមរយៈឧបករណ៍វិទ្យុសម្លេង(Radio Tracking)

-ប្រមូលគ្រាប់ពូជឈើកកោះនៅសហគមន៍ព្រៃឈើនាងកង្រី ខេត្តកំពង់ឆ្នាំង បានចំនួន៥០០គ.ក្រ និងបន្តប្រមូលគ្រាប់ពូជធ្នង់ចំនួន១.០០០គ.ក្រ ដើម្បីយកមកប្រើប្រាស់បណ្តុះកូនឈើរបស់គម្រោងដាំឈើប្រចាំឆ្នាំ២០១៥

-រៀបចំដាំជាចម្ការពូជឈើប្រភេទដូងថែមចំនួន០៥ហិកតា នៅក្នុងស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើអូរបឹងរូង ខេត្តកំពង់ធំ

-បន្តស្រាវជ្រាវពូជឈើមានដោយកម្រនៅក្នុងតំបន់សហគមន៍ព្រៃឈើនានាសម្រាប់ទិសដៅប្រើប្រាស់គ្រាប់ពូជ។

### ៤.៦ ការងារដាំដើមឈើ

-ការដាំឈើក្នុងពិធីបុណ្យរុក្ខទិវា ការដាំឈើជាចម្ការនៅក្នុងស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើរបស់រដ្ឋ ក្រុមហ៊ុនឯកជន ក្រុមហ៊ុនដៃគូជាមួយរដ្ឋបាលព្រៃឈើ ផ្នែកឯកជនខ្នាតតូច/ធំ និងអង្គការក្រៅរដ្ឋាភិបាល និងការថែទាំចម្ការឈើចាស់ បានឈូសឆាយដីព្រៃសរុបចំនួន៧.២៥៦,៥០ហិកតា ដាំឈើជាចម្ការបានចំនួន២.៣៤១,៥០ហិកតា។

**៤.៧ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម**

-ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញឈើកែច្នៃជូនក្រុមហ៊ុនចំនួន៦ ដែលមានបរិមាណឈើចំនួន៧៤.២៩៣ម៣ ឈើអាកាស្យាកាត់កង់ៗចំនួន៥០០ស្ទែរ និងធ្យូងអាកាស្យាចំនួន៣២តោន

-ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលជូនក្រុមហ៊ុនចំនួន០១ ដែលមានបរិមាណឈើអារ និងឈើឡាំងប្រភេទ CHANFUTA ចំនួន១.៣០០ម៣

-ផ្តល់គោលការណ៍នាំចេញឈើកែច្នៃជូនក្រុមហ៊ុនចំនួន៥ ដែលមានបិរមាណឈើកែច្នៃគ្រប់ប្រភេទចំនួន១.៩២៥ម៣ ចំណាំងឈើចំនួន១៣២.៤៥៩តោន និងដើមចន្ទន៍ក្រស្នា(ចម្ការឈើដាំ)ចំនួន១២.២០០ដើម

-ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើសម្រាប់នាំចេញជូនក្រុមហ៊ុនចំនួន០៤ ស្មើនឹង៤០១សន្លឹក ដែលមានបរិមាណឈើកែច្នៃចំនួន៦៥.៥៣៨ម៣ ឈើអាកាស្យាកាត់ជាកង់ៗចំនួន១៦១ស្ទែរ និងធ្យូងអាកាស្យាចំនួន៣២តោន

-ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើសម្រាប់នាំចូលជូនក្រុមហ៊ុនចំនួន០១ ស្មើនឹង០៩សន្លឹក ដែលមានបរិមាណឈើកែច្នៃចំនួន១.១៣២ម៣

-ផ្តល់គោលការណ៍ឲ្យបង្កើតរោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើធុនតូចចំនួន០៧ និងពន្យារសុពលភាពចំនួន០៤ និងបង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើចំនួន៤៧កន្លែង និងពន្យារសុពលភាពចំនួន៣៣។

**៤.៨ ការងារចំណូលព្រៃឈើ**

-ចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើចំនួន៤១.៩២៤.៤៦៦.៨៨១រៀល និងផ្តល់សេវាសាធារណៈចំនួន ៨៥៥.៦១៧,៧៥ដុល្លារ និង៣៤.៤១៤.១០១.០៥០រៀល។

**៤.៩ ការងារនីតិកម្មនិងវិវាទ**

-បង្រ្កាបបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃនៅតាមអង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋានទូទាំងប្រទេសសរុបចំនួន១.៨៩១ករណី ដោយបញ្ជូនទៅតុលាការសរុបចំនួន១.៤៧០ករណី និងពិន័យអន្តរការណ៍ចំនួន៤២១ករណី

-ឃាត់ខ្លួនជនជាប់ចោទនិងដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រុងចំនួន១.៦០១ម៣ ឈើអារចំនួន៤.១៦២ម៣ ឈើគ្រាក់គ្រញូងចំនួន១០៥ម៣និង៧.៤៨៧គ.ក្រ សត្វព្រៃចម្រុះប្រភេទចំនួន១.១៦១គ.ក្រនិង៦៨៩ក្បាល និងអនុផលព្រៃឈើ ព្រមទាំងសម្ភារផ្សេងៗមួយចំនួនទៀត

-ស្តិតិដីព្រៃទទួលរងការកាប់រានសរុបចំនួន២.៦០៨ហិកតា និងដកហូតរណារយន្តចំនួន៨៥គ្រឿង។

## ៥ ផ្នែកជលផល

**៥.១ អាជីវកម្មនេសាទ**

៥.១.១ នេសាទទឹកសាប

-ដាយត្រីក្នុងរដូវនេសាទឆ្នាំ២០១៣-២០១៤ សរុបបានចំនួន២៤.០០០តោន ស្មើ១៦០% នៃផែនការ ១៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១១.០០០តោន(បញ្ចប់រដូវ)

-នេសាទគ្រួសារក្នុងដែននេសាទរដូវឆ្នាំ២០១៤ សរុបបានចំនួន២២០.០០០តោន ស្មើ៥៦,៤១% នៃផែនការ ៣៩០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៤០.០០០តោន

-នេសាទគ្រួសារតាមវាលស្រែក្នុងរដូវឆ្នាំ២០១៤ សរុបបានចំនួន៨៥.០០០តោន ស្មើ៤៧,២២% នៃផែនការ ១៨០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៥.០០០តោន។

៥.១.២ នេសាទសមុទ្រក្នុងឆ្នាំ២០១៤

- អនុវត្តសរុបចំនួន៨០.០០០តោន ស្មើ៧២,៧៣% នៃផែនការ១១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៦.០០០តោន។

**៥.២ វារីវប្បកម្ម**

-ការចិញ្ចឹមត្រីនិងបង្គា សរុបបានចំនួន៧៥.០០០តោន ស្មើ៧៥% នៃផែនការ១០០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១០.០០០តោន

-ការចិញ្ចឹមក្រពើ សរុបបានចំនួន២១៥.០០០ក្បាល ស្មើ៧១,៦៧% នៃផែនការ៣០០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន២៥.០០០ក្បាល

-ការភ្ញាស់កូនត្រីពូជ សរុបបានចំនួនប្រមាណ១៥៥.០០០.០០០កូន ស្មើ៨៦,១១% នៃផែនការ១៨០.០០០.០០០កូន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួនប្រមាណ៥០.០០០.០០០កូន។

**៥.៣ ការកែច្នៃផលនេសាទ**

-ផលនេសាទទឹកសាបក្នុងរដូវនេសាទ២០១៣-២០១៤ សរុបបានចំនួន៥២.០០០តោន ស្មើ៣៤,៦៧% នៃផែនការ១៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន២.០០០តោន

-ផលនេសាទសមុទ្រក្នុងឆ្នាំ២០១៤ សរុបបានចំនួន៦.៥០០តោន ស្មើ៨១,២៥% នៃផែនការ៨.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៥០០តោន

-ការផលិតទឹកត្រី សរុបបានចំនួន៥៥.០០០.០០០លីត្រ ស្មើ៩១,៦៧% នៃផែនការ៦០.០០០.០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១០.០០០.០០០លីត្រ។

**៥.៤ ការនាំចេញផលនេសាទ**

-ផលនេសាទស្រស់ សរុបបានចំនួន៩.០០០តោន ស្មើ៤៥% នៃផែនការ២០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៥០០តោន

-ផលនេសាទកែច្នៃ សរុបបានចំនួន៥.០០០តោន ស្មើ៥០% នៃផែនការ១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៥០០តោន។

**៥.៥ ការអភិរក្សធនធានជលផល**

ក្រោយការកែទម្រង់ស៊ីជម្រៅវិស័យជលផល ឡូត៍នេសាទទាំងអស់នៅទូទាំងប្រទេសបានរំសាយហើយបានបង្កើតជាកន្លែងអភិរក្សជលផលបានចំនួន៤៩១កន្លែង (កន្លែងអភិរក្សជលផលថ្មីចំនួន៥០កន្លែង និងសហគមន៍នេសាទ៣៦៤កន្លែង)។ មកដល់ខែកញ្ញា ក្នុងឆ្នាំ២០១៤នេះ បានបោះបង្គោលបេតុងបានចំនួន៣២ ដើម និងសាងសង់ស្នាក់ការបណ្តែតទឹកបានចំនួន៤ ព្រមទាំងបានដាក់កម្លាំងយាមល្បាតជាប្រចាំ។ សកម្មភាពអភិរក្សជលផលផ្សេងៗទៀតមានដូចខាងក្រោម៖

- អភិរក្សផ្កាថ្ម ស្មៅសមុទ្របានចំនួន៣.៨៣១ហិកតា នៅតាមតំបន់ឆ្នេរ
- ដាំព្រៃលិចទឹកនិងព្រៃកោងកាងបានចំនួន១០០ហិតា
- អភិរក្សអន្លង់ត្រីមេពូជបានចំនួន១៨កន្លែង នៅតំបន់មេគង្គលើ
- រៀបចំតំបន់គ្រប់គ្រងជលផលសមុទ្រគំរូចំនួន១កន្លែង មានទំហំ៤៥០,០០០ហិកតា នៅប្រជុំកោះរ៉ុង កោះរ៉ុងសន្លឹម ខេត្តព្រះសីហនុ ដើម្បីការពារធនធានជលផលនិងជីវចម្រុះ
- ចុះផ្សព្វផ្សាយពីសារៈសំខាន់នៃទីជម្រកធនធានជលផល និងប្រភេទធនធានជលផលកំពុងរងគ្រោះថ្នាក់បានចំនួន១២វគ្គ មានប្រជាជនចូលរួមចំនួន៩០០នាក់
- បានការពារនិងអភិរក្សនូវប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់មួយចំនួនដូចជា៖ កន្ធាយក្បាលកង្កែប ផ្សោតទឹកសាប ល្មិច អណ្តើកសរសៃ សេះសមុទ្រ ក្រពើត្រី ត្រីនាគ ត្រីគល់រាំង និងត្រីរាជ ដែលធ្វើឲ្យចំនួនរបស់វាកើនក្នុងចន្លោះពី៥ទៅ១៥ភាគរយ
- បានរៀបចំទិវាមច្ឆជាតិ០១កក្កដា នៅអាងទឹកក្តុល ស្ថិតនៅភូមិក្រាំងកន្ទ្រោល ឃុំពាម ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

### ៥.៦ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើស

-កំណត់ហេតុបទល្មើស សរុបចំនួន១.៧៧៣ករណី ដែលកើតមាននៅតំបន់ទឹកសាប១.៧១៨ករណី និងតំបន់សមុទ្រ៥៥ករណី ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៣៥៣ករណី គឺតំបន់ទឹកសាបថយចុះ៣៤៣ករណីនិងតំបន់សមុទ្រថយចុះ១០ករណី។ ជំរុញការចុះត្រួតពិនិត្យនិងមានវិធានការដើម្បីលុបបំបាត់បទល្មើសនេសាទតាមគ្រប់រូបភាព។

### ៥.៧ ការប្រមូលថវិកា

-ចំណូលពីវិស័យជលផល សរុបបានចំនួន២.៦៦៦.៨២៩.២៣២រៀល ស្មើ៨៧,៦៥% នៃផែនការ ៣.០៤២.៥០០.០០០រៀល ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៧៤៧.៦៥១.៨៤១រៀល។

## ៦ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

-ចូលរួមប្រជុំនិងសិក្ខាសាលាផ្សេងៗ នៅក្នុងប្រទេសសរុបចំនួន១៣៧លើក និងនៅប្រទេសថៃ នេប៉ាល់ ចិន ជប៉ុន អ៊ីតាលី អូស្ត្រាលី កូរ៉េ និងវៀតណាម សរុបចំនួន១០លើក

-ទទួលដំណើរទស្សនកិច្ចរបស់គណៈប្រតិភូអន្តរក្រសួងនៃប្រទេសបង់ក្លាដេសចំនួន៦រូប ដើម្បីពិភាក្សាការងារស្តីពីផលិតភាពដំណាំកសិកម្មនៅក្នុងប្រទេសកម្ពុជា

-ទទួលជួបធ្វើបទបង្ហាញអំពីលទ្ធផលការងារពិសោធន៍ស្រាវជ្រាវនិងពិភាក្សា ព្រមទាំងផ្តល់ប្រឹក្សាចំនួន៣៣លើក ជាមួយគណៈប្រតិភូភ្ញៀវជាតិនិងអន្តរជាតិចំនួន១៨០នាក់

-ធ្វើពិសោធន៍ចំនួន៧៨ប្រភេទ នៅ៧៣៣កន្លែង ក្នុងនោះមានពិសោធន៍បន្សាំពូជលើស្រែកសិករនិងស្រែបង្ហាញចំនួន៥៣៩កន្លែង

-ធ្វើអង្កេតបានចំនួន១១ប្រភេទ ដោយសម្ភាសន៍កសិករចំនួន២.០០០គ្រួសារ

-ធ្វើការបែងចែកសៀវភៅឯកសារនានាចំនួន១.៤០០ច្បាប់ ព្រមទាំងខិត្តប័ណ្ណនិងព្រឹត្តិបត្រព័ត៌មានកសិករចំនួន ១២.១០០ច្បាប់ ជូនថ្នាក់ដឹកនាំ ក្រុមប្រឹក្សាភិបាល អង្គភាពក្រោមឱវាទក្រសួង មន្ទីរកសិកម្មរាជធានី ខេត្ត ការិយាល័យកសិកម្មស្រុក និងអ្នកពាក់ព័ន្ធ ជាពិសេសដល់កសិករ

-បន្តការអភិរក្សពូជដំណាំដែលមាននៅក្នុងធនាគារពូជ នៅក្នុងផ្ទះសំណាញ់ និងនៅក្នុងចម្ការ លើដំណាំចំនួន៣០ប្រភេទ ក្នុងនោះស្រូវចំនួន៦.២៧៨បញ្ជីក/សំណាក និងដំណាំផ្សេងៗចំនួន២៩ប្រភេទ រួមមាន៩៩៨បញ្ជីក/សំណាក សរុបទាំងអស់ចំនួន៧.២៧៦បញ្ជីក/សំណាក

-បានបញ្ចេញពូជស្រូវដំណើបស្បៃមង្គល ដែលជាពូជស្រូវដំណើបដំបូងនិងជាពូជស្រូវទី៣៩ជូនកសិករប្រើប្រាស់

-ចុះធ្វើទិវាស្រែបង្ហាញនិងវាយតម្លៃចំនួន១២កន្លែង នៅខេត្តតាកែវ ព្រៃវែង ស្វាយរៀង កំពត និងកំពង់ស្ពឺ ដែលមានកសិករចូលរួមសរុបចំនួន១.១៤៥នាក់ និងវគ្គបណ្តុះបណ្តាលកសិករចំនួន៦វគ្គ នៅខេត្តរតនគិរី ស្ទឹងត្រែង និងកែប ដែលមានអ្នកចូលរួមចំនួន៤១៥នាក់

-ការស្រាវជ្រាវរកព័ត៌មានបច្ចេកទេសកសិកម្មក្នុងគេហទំព័រ www.cardi.org.kh និង www.crkb.org.kh មានអ្នកចូលរួមសរុបចំនួន៣០៣.៣៤៣នាក់ គិតជាមធ្យមប្រមាណ១.១២៣នាក់ក្នុងមួយថ្ងៃ កើនលើសមធ្យមភាគប្រចាំឆ្នាំ២០១៣ចំនួន២២៧នាក់ក្នុងមួយថ្ងៃ។

## ៧ ផ្នែករដ្ឋបាល

-ទទួលលិខិតពីក្រសួងនិងស្ថាប័ននានាសរុបចំនួន៣.៩៧៤ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទសរុបចំនួន៣.២៨៤ច្បាប់ និងទទួលពីរាជធានី ខេត្ត សរុបចំនួន១.០៨៩ច្បាប់ និងចាត់ចែងបន្តតាមចរន្តរដ្ឋបាល

-បញ្ជូនឯកសារនិងលិខិតទៅស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី ខេត្ត សរុបចំនួន៦.២០៤ច្បាប់ ប្រកាស សេចក្តីសម្រេច និងសារាចរ សរុបចំនួន៤៧៧ច្បាប់ និងចម្លងចែកទៅអង្គភាពក្រោមឱវាទ សរុបចំនួន៥៣០ច្បាប់

-ក្រៅពីនេះគឺមានការទទួលរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួងនិងការទទួលភ្ញៀវជាតិ អន្តរជាតិ ការចូលរួមរៀបចំពិធីបុណ្យជាតិ អន្តរជាតិជាដើម ...។ល។

## ៨ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

-ក្នុងកិច្ចប្រជុំលើកទី១៤របស់រដ្ឋមន្ត្រីកសិកម្មនិងព្រៃឈើ អាស៊ានបូក៣នៅប្រទេសភូមានាពេលថ្មីៗនេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានទទួលសិទ្ធប្រទានពី សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីចុះហត្ថលេខាលើ៖ ១-អនុស្សរណៈនៃការយោគយល់គ្នារវាងរដ្ឋអាស៊ាន និងសាធារណរដ្ឋប្រជាមានិតចិន ស្តីពីកិច្ចសហប្រតិបត្តិការស្បៀងនិងកសិកម្ម ២-អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការអាស៊ាន និងអភិក្រមចម្រុះក្នុងការជំរុញផលិតផលកសិកម្ម និងព្រៃឈើ និង៣-អនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃប្រទេសសមាជិកអាស៊ាន និងរាជរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការអនាម័យ និងភូតគាមអនាម័យ

-ធ្វើជាម្ចាស់ផ្ទះសម្រាប់រៀបចំកិច្ចប្រជុំអាស៊ាន ៖ (១) កិច្ចប្រជុំលើកទី១០ នៃក្រុមការងារបមាណីអាស៊ានស្តីពីផលិតផលសាកវប្បកម្ម និងកិច្ចប្រជុំពាក់ព័ន្ធ (២) កិច្ចប្រជុំលើទី១៦ នៃក្រុមការងារជំនាញការ និងលើកទី២១ នៃក្រុមការងារដំណាំអាស៊ាន (៣) កិច្ចប្រជុំលើកទី១៧ នៃឧត្តមមន្ត្រីព្រៃឈើអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធ

-រៀបចំលិខិតទៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដើម្បីសុំការអនុញ្ញាតគាំទ្រគោលនយោបាយស្តីពីការនេសាទបាឡែនប្រកបដោយនិរន្តរភាពរបស់ប្រទេសជប៉ុន

-ថ្នាក់ដឹកនាំក្រសួងបានចូលរួមកិច្ចប្រជុំគណៈកម្មាធិការជាតិសម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម និងគណៈកម្មាធិការចម្រុះកម្ពុជា-ឡាវ-វៀតណាម លើកទី៩ និងកិច្ចប្រជុំពាក់ព័ន្ធ

-ថ្នាក់ដឹកនាំក្រសួងបានទទួលជួបសវនាការជាបន្តបន្ទាប់ជាមួយតំណាងស្ថានទូតនានា អង្គការជាតិ-អន្តរជាតិ និងវិស័យឯកជនដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការក្នុងស្មារតីទទួលខុសត្រូវ

-សម្របសម្រួលរៀបចំបែបបទ និងគោលការណ៍ជូនថ្នាក់ដឹកនាំក្រសួង ទីប្រឹក្សាបច្ចេកទេស និងមន្ត្រីរាជការក្រោមឱវាទដូចជាលិខិតឆ្លងដែន ពន្យារទិដ្ឋាការស្នាក់នៅ ព្រមទាំងទៅចូលរួមប្រជុំ សន្និសីទ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាបានចំនួន៥៨រូប នៅក្នុងប្រទេសចំនួន១០។

## ៩ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស និងទស្សនកិច្ចសិក្សាក្រៅប្រទេស

ក្របខណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន៦.៦១៦នាក់ នារីចំនួន១.២៦៥នាក់ ស្មើនឹង១២% រួមមាន៖

-អង្គភាពថ្នាក់កណ្តាលចំនួន៤.០៨៣នាក់ ក្នុងនោះនារីចំនួន៧៤២នាក់ ស្មើនឹង១៨,១៧%

-អង្គភាពថ្នាក់រាជធានី ខេត្តចំនួន២.៥៧៣នាក់ ក្នុងនោះនារីចំនួន៥៣១នាក់ ស្មើនឹង២០,៦៣%

-ប្រកាសតែងតាំងតម្លើងឋានៈមន្ត្រីរាជការសរុបចំនួន៤០១នាក់ ស្ត្រីចំនួន៦៦នាក់

-ប្រកាសលុបឈ្មោះមន្ត្រីចេញពីក្របខណ្ឌចំនួន៦២នាក់ ក្នុងនោះបោះបង់ការងារចំនួន១១នាក់ សុំលាឈប់ពីការងារចំនួន១៨នាក់ និងមរណភាពចំនួន៣៣នាក់

-ប្រកាសផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួងចំនួន៨នាក់ ផ្ទេរចូលក្រសួងចំនួន៩នាក់ និងផ្ទេរចេញ-ចូលផ្ទៃក្នុងក្រសួងចំនួន៦៨នាក់

-រៀបចំផែនការក្របខ័ណ្ឌថវិកាមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និងពលករអណ្តែតឆ្នាំ២០១៤ សរុបចំនួន២.៨៨៤នាក់ ក្នុងនោះមាន មន្ត្រីក្របខ័ណ្ឌ"ក" ចំនួន៤០៧នាក់ មន្ត្រីក្របខ័ណ្ឌ"ខ" ចំនួន១៨៦នាក់ មន្ត្រីក្របខ័ណ្ឌ"គ" ចំនួន៣០នាក់ បុគ្គលិកជាប់កិច្ចសន្យាចំនួន៦៤៧នាក់ និងពលករអណ្តែតចំនួន១.៦១៤នាក់

-បានរៀបចំប្រឡងជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មីដែលក្រសួងមុខងារសាធារណៈបែងចែកឲ្យមកមានចំនួន៣០៧នាក់ និងបានប្រឡងប្រជែងផ្ទៃក្នុងប្តូរប្រភេទក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលចំនួន៣៤៥នាក់ ក្នុងឆ្នាំ២០១៤នេះ

-ថ្នាក់ដឹកនាំ មន្ត្រីរាជការក្រោមឱវាទបានទៅចូលរួមវគ្គបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លីចំនួន៤០នាក់ ស្ត្រីចំនួន០៧នាក់ និងបណ្តុះបណ្តាលក្រៅប្រទេសមាន៖ ថ្នាក់បណ្ឌិតចំនួន០១នាក់ ថ្នាក់អនុបណ្ឌិតចំនួន១២នាក់ (ស្ត្រីចំនួន០៥នាក់) និងបណ្តុះបណ្តាលរយៈពេលខ្លីចំនួន២១០នាក់ ស្ត្រីចំនួន៣៧នាក់

-រៀបចំធ្វើអត្តសញ្ញាណប័ណ្ណមន្ត្រីរាជការក្របខណ្ឌថ្មី និងបានរៀបចំធ្វើនិយតកម្មដល់មន្ត្រីរាជការថ្នាក់កណ្តាល និងរាជធានី ខេត្ត

-មន្ត្រីបានបើកប្រាក់បៀវត្សតាមប្រព័ន្ធធនាគារមានចំនួន៣.៨៦៤នាក់ នៅថ្នាក់មូលដ្ឋាន និងចំនួន៥.០១៣នាក់ នៅថ្នាក់រាជធានី ខេត្ត

-ពិនិត្យនិងកែតម្រូវលើការប្រែប្រួលនៃស្ថានភាពបុគ្គលិក និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការគ្រប់អង្គភាពថ្នាក់កណ្តាល បញ្ចូលក្នុងតារាងបៀវត្សថ្មីតាមប្រព័ន្ធព័ត៌មានវិទ្យា។

## ១០ ការងារអប់រំ បណ្តុះបណ្តាលកសិកម្ម

### ១០.១ សាលាជាតិកសិកម្មព្រែកលៀប

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៣-២០១៤ សរុបចំនួន១.៥២៤នាក់(ស្រី៤៩៧នាក់) ក្នុងនោះមាននិស្សិតអាហារូបករណ៍ និស្សិតបង់ថ្លៃ និងនិស្សិតបណ្តុះបណ្តាលបន្តថ្ងៃសៅរ៍-អាទិត្យ ដែលកំពុងសិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សាកវប្បកម្ម សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម កសិឧស្សាហកម្ម និងសុរិយោដី។ សាលាជាតិកសិកម្មព្រែកលៀបបានរៀបចំការការពារសារណាសម្រាប់និស្សិតសរុបចំនួន៤០៣នាក់(នារី១២៨នាក់)លើមុខជំនាញចំនួន៩ និងប្រជុំរៀបចំកម្មវិធីសិក្សាថ្មី២០១៤-២០១៥ ព្រមទាំងសិក្សាអំពីលទ្ធភាពកាត់បន្ថយចំនួនម៉ោងនិងក្រេឌីតក្នុងក្របខណ្ឌកំណែទម្រង់កម្មវិធីសិក្សាឲ្យបានល្អប្រសើរ។

### ១០.២ សាលាជាតិកសិកម្មកំពង់ចាម

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៣-២០១៤ សរុបមានចំនួន១.៣៩៥នាក់(ស្រី៥២២នាក់) រួមមាន៖

-និស្សិតអាហារូបករណ៍សរុប១.១៦៩នាក់(ស្រី៤៥៤នាក់) ក្នុងនោះថ្នាក់បរិញ្ញាវិទ្យាសាស្ត្រកសិកម្ម៩៤៣នាក់(ស្រី៣៣២នាក់) និងថ្នាក់បរិញ្ញារងបច្ចេកទេសកសិកម្ម២២៦នាក់(ស្រី១២៥នាក់) ដែលកំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

-និស្សិតសិក្សាបង់ថ្លៃ២២៦នាក់ (ស្រី៦៨នាក់) ថ្នាក់បរិញ្ញាចំនួន២១៣នាក់(ស្រី៦៥នាក់) និងថ្នាក់បរិញ្ញារងចំនួន១៣នាក់(ស្រី៣នាក់) កំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផលដំណាំកៅស៊ូ និងសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ។

### ១០.៣ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

និស្សិតដែលកំពុងសិក្សាមានចំនួនសរុប៥.៩៧៧នាក់ (ស្រី១.៤០០នាក់) ចែកចេញជា១០មហាវិទ្យាល័យគឺមហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល បច្ចេកវិទ្យានិងគ្រប់គ្រងកសិកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ កសិឧស្សាហកម្ម រៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញាវិទ្យាសាស្ត្រនិងសាលាក្រោយឧត្តម បណ្តុះបណ្តាលលើកម្មវិធីបរិញ្ញារងបរិញ្ញាបត្រ បរិញ្ញាជាន់ខ្ពស់ និងថ្នាក់បណ្ឌិតវិទ្យាសាស្ត្រ។ សាកលវិទ្យាល័យទទួលនិស្សិតដែលបញ្ចប់កម្មសិក្សាដោយជោគជ័យពីប្រទេសអ៊ីស្រាអែលចំនួន៤០នាក់ និងបញ្ជូននិស្សិតថ្មីទៅធ្វើកម្មសិក្សានៅអ៊ីស្រាអែលចំនួន៦០នាក់បន្ថែមទៀត។ សាស្ត្រាចារ្យនិងនិស្សិតចំនួន១២នាក់បានចូលរួមទស្សនកិច្ចនៅសាកលវិទ្យាល័យខនខេន ប្រទេសថៃ រយៈពេលមួយសប្តាហ៍។

ជារួមគ្រឹះស្ថានឧត្តមសិក្សាកសិកម្មទាំង៣ខាងលើតែងតែបញ្ជូននិស្សិតឲ្យចុះធ្វើកម្មសិក្សានៅតាមអង្គភាពជំនាញនៅទីវាល និងតាមបណ្តាក្រុមហ៊ុនមួយចំនួនដើម្បីផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែងក៏ដូចជាការបង្ហាត់ឲ្យចេះកែច្នៃកសិផលមួយចំនួនសម្រាប់ការធ្វើកសិពាណិជ្ជកម្មរួមទាំងការពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូឲ្យកាន់តែទូលំទូលាយ។

### III-សេចក្តីសន្និដ្ឋាននិងវាយតម្លៃ

ជារួមស្ថានភាពការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៤ បានកត់សម្គាល់ឃើញថា បរិមាណទឹកភ្លៀងបានធ្លាក់ជាមធ្យមគ្រប់តំបន់ទូទាំងប្រទេស។ មកទល់ពេលនេះ ល្បឿនការងារដាំដុះដំណាំស្រូវសម្រេចបាន១០០,៣៨ភាគរយនៃផែនការនិងមានសភាពយឺតជាងឆ្នាំមុន(៤,០៧ភាគរយ) បើប្រៀបធៀបរយៈពេលដូចគ្នា ហើយខេត្តចំនួន១២ត្រូវបានបញ្ចប់ និងអនុវត្តលើសផែនការ (លើកលែងតែខេត្តរតនគិរីសម្រេចបាន២៥.៩២៥ហិកតា ស្មើនឹង៩៧,៨៣ភាគរយនៃផែនការ២៦.៥០០ហិកតា)។ ជាមួយនេះ ប្រជាកសិករកំពុងបន្តការងារបង្កបង្កើនផលដំណាំរដូវវស្សាយ៉ាងសកម្ម ជាពិសេសខិតខំជំរុញការថែទាំសន្ទូងនិងធ្វើកសិកម្មសម្រុះ។ រីឯការខូចខាតដំណាំស្រូវដោយគ្រោះធម្មជាតិមកទល់ពេលនេះ អាចវាយតម្លៃជារួមប្រមាណ១.៥៩ភាគរយ នៃផ្ទៃដីអនុវត្តបាន។ ក្រសួងក៏បានណែនាំដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្មរាជធានី ខេត្ត បន្តវាយតម្លៃផលប៉ះពាល់ ក៏ដូចជាការខូចខាតលើផលដំណាំ ជាពិសេសជួយអន្តរាគមន៍ស្តារឡើងវិញលើការប៉ះពាល់ខូចខាតដោយគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត។ ថ្វីបើស្ថានភាពទឹកជំនន់ស្រកអស់ទៅវិញក៏ពិតមែន តែស្ថានភាពសុខភាពសត្វមានការថយចុះ សត្វបាត់កម្លាំងដែលជាមូលហេតុធ្វើឲ្យសត្វងាយនឹងឆ្លងជំងឺផ្សេងៗ រួមទាំងជំងឺប៉ារ៉ាសិតផងដែរ។ ស្ថិតក្នុងស្ថានភាពនេះ អង្គភាពជំនាញនៅតែបន្តសហការជាមួយអ្នកពាក់ព័ន្ធ បន្តតាមដានស្ថានភាពសុខភាពសត្វ ពិនិត្យនិងព្យាបាលសត្វ ផ្តល់ទឹកនិងចំណី។ល។ ក្រសួងកំពុងបន្តចុះពិនិត្យនិងតាមដានលើស្ថានភាពជំងឺសត្វ ដោយបានចាត់ក្រុមការងារចុះណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្មរាជធានីខេត្ត ឲ្យចុះតាមដានជាប្រចាំដើម្បីត្រៀមនិងចាត់វិធានការទប់ស្កាត់បង្ការការពារជំងឺសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង។

ដោយឡែក ការគ្រប់គ្រងធនធានធម្មជាតិ ព្រៃឈើ និងជលផល កំពុងស្ថិតនៅតែជាប្រធានបទអាទិភាព ហើយដែលអង្គភាពជំនាញជាសេនាធិការត្រូវតែខិតខំបន្តសកម្មភាពដូចភ្លៀងរលឹម ជាមួយនឹងការបន្តពង្រឹងការអនុវត្តច្បាប់និងបទដ្ឋានផ្សេងៗជាធរមាន។ លើសពីនេះទៅទៀត ផ្នែកសេវាកម្ម ដំណើរការនៃការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ កិច្ចសហប្រតិបត្តិការអន្តរជាតិ និងការគាំទ្រផ្សេងៗក៏បានសម្រេចនូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍និងទិសដៅរបស់រាជរដ្ឋាភិបាល។

### IV- ទិសដៅអនុវត្តបន្ត

**១.ផ្នែកដាំដុះ :**

-តាមដាននិងអន្តរាគមន៍ចំពោះការផ្ទុះរាលដាល និងការបំផ្លាញដោយសត្វល្អិតដាយថាហេតុចំពោះដំណាំកសិកម្មផ្សេងៗ

-តាមដានចលនានាំចេញស្រូវនិងផ្លែស្រូវ ជាពិសេសតាមច្រកព្រំដែននានា

-បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំផ្សេងទៀត ឬប្រើប្រាស់ពូជស្រូវសមស្របជាមួយនឹងការប្រើប្រាស់ទឹកដោយប្រសិទ្ធភាព ជាពិសេសចំពោះខេត្តដែលមានអគុល្យភាពស្មៀង (អង្គរ) ដោយជំរុញកសិករឲ្យឆ្លៀតឱកាសដាំដំណាំរួមផ្សំ ដូចជា ៖ ពោត ដំឡូង បន្លែ សណ្តែក។ល។ ដើម្បីបានផ្តល់កម្រៃបន្ថែមដល់សេដ្ឋកិច្ចគ្រួសារ

-បន្តអប់រំផ្សព្វផ្សាយ និងជួយដល់ប្រជាកសិករក្នុងការតម្កល់និងរក្សាទឹកសម្រាប់ប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃនិងការបង្កបង្កើនផល

-ពិនិត្យពង្រឹងឡើងវិញ ដើម្បីត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារនានាសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ដើម្បីទប់ទល់ជំងឺឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ បន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ក៏ដូចជាការរៀបចំគំរូនៃការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិពាណិជ្ជកម្ម

-ត្រៀមប្រជុំបូកសរុបការងារបង្កបង្កើនផលដំណាំស្រូវវស្សាឆ្នាំ២០១៤ នៅចុងឆ្នាំនេះ

-អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍កូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសទៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ

-ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

-ត្រៀមធ្វើការដាំដុះសាកល្បងក្លូនកៅស៊ូប្រភេទ "In vitro"។

**២.ផ្នែកផលិតកម្មបសុព្យាបាល** :

-បន្តចាត់វិធានការដោយសហការជាមួយស្ថាប័ននិងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានជាបន្តលើសភាពការណ៍ជំងឺសត្វ និងចាត់ក្រុមការងារចុះអប់រំណែនាំនិងជំរុញអង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្មរាជធានី ខេត្ត ស្រុក ដើម្បីត្រៀមនិងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង។ ទន្ទឹមនឹងនោះ ត្រូវធ្វើការអប់រំណែនាំដល់ប្រជាកសិករឲ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឲ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្ត

-រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តារាជធានី ខេត្ត

-ថែទាំសុខភាព តាមដានជំងឺសត្វ និងមានវិធានការអន្តរាគមន៍តាមការចាំបាច់

-ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យនៅកន្លែងផ្ទុះជំងឺនិងកន្លែងដែលមានការឆ្លងរាលដាលជំងឺផ្តាសាយបក្សី H5N1 និងជំងឺផ្តាសាយ H7N9

-ពង្រឹងទប់ស្កាត់ចរាចរណ៍សត្វនិងផលិតផលសត្វខុសច្បាប់តាមទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ

-ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកក្រចៀកខៀវ ប៉េស្ត និងវិធានការទប់ស្កាត់នៅតាមរាជធានី ខេត្ត

-ចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី ខេត្ត

-បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ ដែលនឹងត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាពេលឆាប់ៗខាងមុខ។

**៣.ផ្នែកព្រៃឈើ** :

-ជំរុញដាក់ឲ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការនិងតាមការពិន័យអន្តរការណ៍

-បន្តតាមដានត្រួតពិនិត្យនិងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីវិស័យព្រៃឈើតាមរយៈការលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ ការពង្រឹងនិងពង្រីកសហគមន៍ព្រៃឈើឲ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីៗ ព្រមទាំងអប់រំផ្សព្វផ្សាយដល់ប្រជាសហគមន៍ឲ្យងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនពឹងអាស្រ័យទៅលើតែផល អនុផលព្រៃឈើនោះឡើយ

-បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើនិងភាគីពាក់ព័ន្ធ តាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើសត្វព្រៃ និងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍

-បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើសត្វព្រៃតាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ

-កំណត់តំបន់ព្រៃឈើរេចរឹលឲ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឲ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើ

-បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឲ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់

-ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ និង០២។

**៤.ផ្នែកជលផល** :

-ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងវិស័យជលផល

-រៀបចំបោះបង្គោលបេតុងចំនួន១៥០បង្គោលនិងសាងសង់ស្នាក់ការល្បាតចំនួន១៦កន្លែងនៅកន្លែងអភិរក្សជលផល

-បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ

-រៀបចំនិងអនុវត្តវិធានការការពារដែននេសាទនិងធនធានជលផល

-បន្តស្រាវជ្រាវជកហូតនិងបោះបង្គោលដីព្រៃលិចទឹកដែលកាន់កាប់អនាធិបតេយ្យដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ

-រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃ

-បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឲ្យបានគ្រប់ឃុំ

-ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៤ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី បង្គា ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទនិងការបង្កើនផលចំណូលថវិកាជាតិ

-បន្តជំរុញការត្រួតពិនិត្យ និងតាមដានការបង្ក្រាបបទល្មើសនេសាទដូចភ្លៀងរលឹម។

**៥.ផ្នែកពាក់ព័ន្ធផ្សេងៗ** :

-បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ស្តីពីថ្នាំកសិកម្មនិងជីកសិកម្មនៅតាមបណ្តាខេត្ត រាជធានី

-ពង្រឹងការងារបញ្ជីការគណនេយ្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្មរាជធានី-ខេត្ត ក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីនៅឆ្នាំ២០១៥ ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ

-បន្តចុះពិនិត្យផ្ទាល់ដល់ទីវាលរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឲ្យបានច្បាស់លាស់និងការប្រមូលចំណូលបង់ចូលថវិកាជាតិ

-បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមវិស័យទាំងក្នុងនិងក្រៅប្រទេសឲ្យបានទូលំទូលាយ

-បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទតាមផែនការឆ្នាំដែលបានគ្រោងទុក និងតាមសកម្មភាពជាក់ស្តែង

-ពង្រឹងការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សឲ្យបានសមស្របទៅតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា

-បន្តរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ច្បាប់ស្តីពីសហគមន៍កសិកម្ម ដើម្បីធានាដល់ប្រសិទ្ធភាពពេញលេញក្នុងការអនុវត្ត

-បន្តរៀបចំច្បាប់ផ្សេងៗទៀតតាមផ្នែកនីមួយៗតាមការចាំបាច់ ដូចជាច្បាប់ស្តីពីកៅស៊ូ ច្បាប់ស្តីពីការគ្រប់គ្រងដីកសិកម្ម ច្បាប់ស្តីពីសត្វព្រៃនិងជីវចម្រុះ ច្បាប់ស្តីពីគុណភាព និងសុវត្ថិភាពផលិតផលកសិកម្មដើម្បីធានាដល់ដំណើរការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទឲ្យបានសមស្រប។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ [illegible] ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**